ទីស្តីការក្រសួងយុត្តិធម៌
លេខ ០១.កយ.សណន-០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# <u>សេចក្តីណែនាំរួម</u>

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោកប្រធានតុលាការកំពូល

**<u>ជម្រាបមក</u>**

លោក លោកស្រី ប្រធាន អនុប្រធាន និងចៅក្រម គ្រប់តុលាការខេត្ត-ក្រុង

លោក លោកស្រី ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារ អមតុលាការខេត្ត-ក្រុង

**<u>កម្មវត្ថុ</u>:** អំពីការអនុវត្តន៍ច្បាប់ស្តីពីបទល្មើស បរិហាកេរ្តិ៍ ក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**<u>យោង</u>:** -មាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ

-ច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល

-ច្បាប់ស្តីពីសារព័ត៌មាន

-សេចក្តីថ្លែងការណ៍ជាសកលនូវសិទ្ធិនៃមនុស្ស

-កត្តិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និង សិទ្ធិនយោបាយ

-សេចក្តីសម្រេចលេខ ០៦៣/០០៥/២០០៤ កបធច ចុះថ្ងៃ០៦ ខែតុលា ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីបទ បរិហាកេរ្តិ៍ និងជេរប្រមាថ

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានកត់សម្គាល់ឃើញថា ការអនុវត្តន៍មាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលស្តីពីបទបរិហាកេរ្តិ៍ និងជេរប្រមាថបានជួបការលំបាកច្រើនដោយមូលហេតុថាច្បាប់នេះ បានតម្រូវឱ្យផ្តន្ទាទោសដាក់គុកពី០៨ថ្ងៃ ទៅ០១ ឆ្នាំផង និងផ្តន្ទាទោសពិន័យជាប្រាក់ផង ឬផ្តន្ទាទោសតែទោសណាមួយក៏បាន ។

ហេតុដូច្នេះ ក្រសួងយុត្តិធម៌ និងតុលាការកំពូលសូមធ្វើការណែនាំដូចតទៅ ៖

ក-ក្នុងករណីជនណា ដែលបានប្រព្រឹត្តអំពើបរិហាកេរ្តិ៍ ឬអំពើជេរប្រមាថ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល តុលាការគប្បីអនុវត្តត្រឹមតែទោសពិន័យនោះបានហើយ ។ បើសិនជាមានបណ្តឹងសំណងរដ្ឋប្បវេណី គប្បីសម្រេចដោយថ្លឹងថ្លែងដល់ផលប៉ះពាល់នៃការខូចខាតនោះ ។

ខ-ក្នុងករណីជនណា ដែលបានប្រព្រឹត្តិអំពើបរិហាកេរ្តិ៍ ឬជេរប្រមាថទៅលើបុគ្គលឯកជន ឬបុគ្គលសាធារណៈហើយ អាចបង្កលក្ខណៈឱ្យមានអស្ថេរភាព ដល់សន្តិសុខសាធារណៈសណ្តាប់ធ្នាប់សង្គម ឬធ្វើអោយមានភាពវឹកវរ ចលាចល ដល់ស្ថេរភាពនយោបាយ និងសន្តិសុខជាតិ នោះត្រូវអនុវត្តតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោក លោកស្រីដែលជាចៅក្រម នឹងយកចិត្តទុកដាក់ក្នុងការអនុវត្តអោយបានល្អតាមការណែនាំខាងលើនេះ ដើម្បីការពារសិទ្ធរបស់ប្រជាពលរដ្ឋក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋលើប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា ។

ភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

**ប្រធានតុលាការកំពូល** **រដ្ឋមន្ត្រី**

**ឌិត មុន្ទី** **អង្គ វង្សវឌ្ឍានា**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

-ខុទ្ទកាល័យសម្តេចព្រះប្រធានរដ្ឋសភា។

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការ

-ឯកសារ - កាលប្បវត្តិ